| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | ចិត្តចលភាព/ បុរេគណិត |
| **ប្រធានបទ** | (ចិត្តចលភាព) ការហ្វឹកហាត់បង្កើនកម្លាំង និង សម្របសម្រួលរវាងចលនាសាច់ដុំនិងចលនាសាច់ភ្នែក។<br>(បុរេគណិត) បញ្ញត្តិរង្វាស់រង្វាល់។ |
| **ចំណងជើងមេរៀន** | ល្បែងតម្រង់ជួរ ដកស្រង់ចេញពី<br>"រឿង យក្សចម្លែក" |
| **កម្រិត** | គ្រប់កម្រិត |
| **គោលបំណង** | (ចិត្តចលភាព) ប្រាប់ពីរបៀបវិធីដើរ បង្វិល់ខ្លួន ទៅតាមគោលដៅនិងចម្ងាយដែលបានកំណត់ ។<br>(បុរេគណិត) ប្រាប់បានពីបញ្ញត្តិ ខ្ពស់និងទាប តូចនិងធំ វែងនិងខ្លី ធ្ងន់និងស្រាល តិចនិងច្រើន គ្មាននិងមាន ពេញនិងកន្លះ ។ |
| **បំណិនសម្បទា** | (ចិត្តចលភាព) កំណត់ចំណុចគោលនៃចលនាដៃដោយការទប់លំនឹងនិងសម្របសម្រួលទៅនិងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ។<br>(បុរេគណិត) ប្រៀបធៀបខ្ពស់ និងទាប តូចនិងធំ វែង និងខ្លី គ្មាននិងមាន ធ្ងន់និងស្រាល តិចនិងច្រើន ពេញនិងកន្លះដោយប្រើខ្នាត។ |
| **ចរិយាសម្បទា** | (ចិត្តចលភាព) មានអំណត់តស៊ូព្យាយាម និង សប្បាយរីករាយក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ និង ជោគជ័យ។<br>(បុរេគណិត) សហការ និងអំណត់ព្យាយាមក្នុងការវាស់ វាល់ ថ្លឹង និងប្រៀបធៀប។ |
| **គ្រូបង្រៀន**<br>**(ផលិតសម្ភារឧបទេស)** | បង្កើតពាក្យ ខ្ពស់ ទាប វែង ឬខ្លី។ |
| **កុមារ** | កុមារស្តាប់ដោយយកចិត្តទុកដាក់។ |
| **រៀបចំ** | -បែងចែកកុមារជាក្រុម។<br>-ឱ្យកុមារតម្រង់ជួរ ។<br>-ពន្យល់កុមារពីរបៀបលេង។ |

| **សកម្មភាពគ្រូបង្រៀន** | **មាតិកា** | **សកម្មភាពសិស្ស** |
|---|---|---|
| ១. និយាយពីយក្សដែលមានកម្ពស់ខ្ពស់ ។<br>២. សួរក្មេងៗទាំងអស់ប្រសិន | ១. ក្មេងម្នាក់ឈរនៅកន្លែងមួយ ។<br>២. ក្មេងម្នាក់ទៀតឈរនៅបន្ទាប់ក្មេងទីមួយនោះ។ | ១. ស្តាប់គ្រូដោយចិត្តទុកដាក់ ។<br>២. ពន្យល់ពាក្យប្រសិនបើអ្នកស្គាល់ពាក្យហ្នឹង ។ |

| | | |
|---|---|---|
| បើពួកគេស្គាល់ពា ក្យថា ខ្ពស់<br>៤. សួរក្មេងៗទាំងអស់ប្រសិន<br>បើពួកគេស្គាល់ពា ក្យផ្ទុយពី<br>ពាក្យខ្ពស់។<br>៤. សុំឱ្យក្មេងៗប្រាប់ពីឧ.ម្នាក់<br>មួយចំនួនពីពាក្យថា ខ្ពស់<br>និងពាក្យទាប។<br>៥. ណែនាំពាក្យប្រៀបធៀប<br>ពីពាក្យទាំង២៖<br>«ខ្ពស់ជាង» «ខ្ពស់បំផុត»<br>និង«ទាបជាង»«ទាបបំផុត»។<br>៦.បែងចែកក្មេងៗទៅជាក្រុម។<br>ចំនួនសម<br>ជិកក្នុងក្រុមទាំងនោះអាស្រ័យលើថាតើអ្ន<br>កចង់<br>ឱ្យសកម្មភាពនេះពិបាកយ៉ាង<br>ណា។<br>ក្មេងៗកាន់តច្រើនក្នុងក្រុមនោះកាន់តែពិ<br>បាកដែរ។<br>៧. ឱ្យក្មេងតម្រង់ជួរទៅតាម<br>ក្រុមរបស់ខ្លួនគឺចាប់ផ្ដើមពីទាបទៅខ្ពស់<br>។<br>៨. សួរសំណួរទៅកាន់ក្មេងៗ ថា<br>«តើក្មេងម្នាក់នេះខ្ពស់ ឬ<br>ទាបជាងក្មេងម្នាក់នោះ?» ។<br>៩.<br>សួរក្មេងៗបែបនេះរហូតដល់ក្មេងៗខ្ពស់<br>ជាងគេ។ | ៣.ក្មេងទី៣ត្រូវជ្រើសរើស<br>កន្លែងដែលខ្លួនអាចឈរបានដែលថាខ្លួន<br>ឯងខ្ពស់ជាង ឬ ទាបជាង<br>ក្មេងទាំង២នាក់នោះ។<br>៤.ក្មេងទី៤ត្រូវដើរមួយជុំជួរ<br>សិន។បន្ទាប់មកត្រូវស្វែងរកកន្លែងដែល<br>ខ្លួនអាចឈរ<br>បានទៅតាមកម្ពស់ របស់ខ្លួន ។<br>៥.<br>បន្តឱ្យក្មេងៗឈរក្នុងជួរទាំងអស់ពីទាប<br>ទៅខ្ពស់<br>ឬពីខ្ពស់ទៅទាបជាជួរជាការស្រេចល្បែង<br>នេះអាច<br>លេងបានជា ច្រើន ជុំ។<br>អាចបន្ថែមចំនួនក្មេងថែម ទៀត<br>ប្រសិនបើមើលទៅ<br>ហាក់ដូចជាងាយស្រួល<br>ពេក។ | ៣. ឱ្យឧទាហរណ៍.ប្រសិនបើអ្នកអាច ។<br>៤. ដឹងថា ខ្លួនឯងត្រូវ<br>ឈរនៅទីណាដែលខ្ពស់។<br>៥. ឆ្លើយសំណួរគ្រូ។ |